# សំណួរចោទសួរជាញឹកញាប់អំពីឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ដែលផុតកំណត់

**កុំអាលបោះចោលឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ដែលផុតកំណត់។ នេះជាវិធីដើម្បីដឹងថាឧបករណ៍ធ្វើតេស្តជំងឺ COVID-19 របស់អ្នកនៅមានគុណភាពឬអត់ ក្នុងការប្រើហួសកាលបរិច្ឆេទកំណត់ដែលបានចុះលើប្រអប់។**

## តើខ្ញុំអាចប្រើឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ដែលផុតកំណត់បានទេ?

បាន។ Washington State Department of Health (DOH, ក្រសួងសុខាភិបាល) នៃរដ្ឋវ៉ាស៊ីនតោនបានចេញលិខិតអនុញ្ញាតជាផ្លូវការឱ្យប្រើប្រាស់ឧបករណ៍ធ្វើតេស្តដែលផុតកំណត់ (ជាភាសាអង់គ្លេស) ឱ្យតែឧបករណ៍ធ្វើតេស្តនោះឆ្លងផុតការត្រួតពិនិត្យគុណភាពដោយជោគជ័យ ដែលយើងពន្យល់ដូចខាងក្រោម។

បន្ថែមពីនេះ ឧបករណ៍ធ្វើតេស្តជំងឺ COVID-19 មួយចំនួនទទួលបានការពន្យារអាយុកាលប្រើប្រាស់ពី U.S. Food and Drug Administration (FDA, រដ្ឋបាលចំណីអាហារនិងឱសថ) នៃសហរដ្ឋអាមេរិក ដែលផ្តល់កាលបរិច្ឆេទផុតកំណត់ថ្មីដល់ឧបករណ៍ធ្វើតេស្តទាំងនោះ ដែលខុសពីអ្វីដែលអ្នកមើលឃើញលើប្រអប់។ អ្នកអាចពិនិត្យមើលបញ្ជីឧបករណ៍ធ្វើតេស្តដែលមានការពន្យារអាយុកាលប្រើប្រាស់របស់ FDA (ជាភាសាអង់គ្លេស និងអេស្ប៉ាញ) ដើម្បីមើលថាតើឧបករណ៍ធ្វើតេស្តណាខ្លះមានកាលបរិច្ឆេទផុតកំណត់ថ្មី។ យោងតាម DOH ទោះជាឧបករណ៍ធ្វើតេស្តមួយមានកាលបរិច្ឆេទផុតកំណត់ដែលឥឡូវនេះកន្លងផុតហើយក៏ដោយ ក៏អ្នកនៅតែអាចប្រើវាបានដែរ ប្រសិនបើវាឆ្លងផុតការត្រួតពិនិត្យគុណភាពដោយជោគជ័យ។

ចំណុចសំខាន់៖ អ្នកអាចប្រើឧបករណ៍ធ្វើតេស្តដែលផុតកំណត់បាន ឱ្យតែវាឆ្លងផុតការត្រួតពិនិត្យគុណភាពដែលមានស្រាប់ដោយជោគជ័យ។

## តើធ្វើម៉េចទើបខ្ញុំដឹងថា ឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ដែលផុតកំណត់នឹងផ្តល់លទ្ធផលត្រឹមត្រូវដល់ខ្ញុំ?

ឧបករណ៍ធ្វើតេស្តជំងឺ COVID-19 របស់អ្នកនឹងភ្ជាប់មកជាមួយការណែនាំអំពីជំហានដែលត្រូវធ្វើ ដើម្បីឱ្យប្រាកដថាឧបករណ៍ធ្វើតេស្តមានប្រសិទ្ធភាពគួរឱ្យទុកចិត្តបាន ដែលហៅម្យ៉ាងទៀតថា "ការត្រួតពិនិត្យគុណភាព"។ ជាធម្មតា អ្នកអាចរកឃើញដំណើរការត្រួតពិនិត្យគុណភាពនៅក្នុងផ្នែកលទ្ធផលធ្វើតេស្តក្នុងក្រដាសណែនាំអំពីការធ្វើតេស្ត។ ដំណើរការត្រួតពិនិត្យគុណភាពសម្រាប់ឧបករណ៍ធ្វើតេស្តនៅផ្ទះជាច្រើនគឺគ្រាន់តែធ្វើឱ្យប្រាកដថា ឆ្នូតនៅជិតអក្សរ "C" លើបន្ទះធ្វើតេស្តនឹងបង្ហាញឱ្យឃើញ នៅពេលដាក់សំណាកលើវា។ ប្រសិនបើដំណើរការត្រួតពិនិត្យគុណភាពមិនបានជោគជ័យទេ អ្នកគួរតែបោះចោលឧបករណ៍ធ្វើតេស្តនោះ។

## តើឧបករណ៍ធ្វើតេស្តទទួលបានការពន្យារអាយុកាលប្រើប្រាស់តាមរបៀបណា?

ក្រុមហ៊ុនផលិតឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ត្រូវបានតម្រូវឱ្យធ្វើការស្រាវជ្រាវដែលពិនិត្យលើរយៈពេលដែលអាចប្រើប្រាស់ឧបករណ៍ធ្វើតេស្តបាន។ FDA តាមដានទិន្នន័យនេះ ដើម្បីអនុញ្ញាតលើការពន្យារកាលបរិច្ឆេទផុតកំណត់។ ការពន្យារអាយុកាលប្រើប្រាស់ឧបករណ៍ធ្វើតេស្តជំងឺ COVID-19 គឺជារឿងធម្មតា ដោយសារមានទិន្នន័យចូលមកកាន់តែច្រើនអំពីរយៈពេលដែលអាចប្រើប្រាស់ឧបករណ៍ធ្វើតេស្តទាំងនេះបាន។

យើងសង្ឃឹមថា ព័ត៌មាននេះធ្វើឱ្យអ្នកច្បាស់ក្នុងចិត្តវិញនៅពេលប្រើប្រាស់ឧបករណ៍ធ្វើតេស្តដែលហាក់ដូចជាផុតកំណត់ហើយ ដោយមើលតាមកាលបរិច្ឆេទផុតកំណត់លើប្រអប់។ ឥឡូវនេះ អ្នកដឹងថាត្រូវធ្វើម៉េចដើម្បីបញ្ជាក់ថាតើឧបករណ៍ធ្វើតេស្តជំងឺ COVID-19 របស់អ្នកនៅមានគុណភាពល្អក្នុងការប្រើប្រាស់ឬអត់៖ គ្រាន់តែធ្វើតាមការណែនាំអំពីការធ្វើតេស្ត ដើម្បីត្រួតពិនិត្យគុណភាព។ ប្រសិនបើឧបករណ៍ធ្វើតេស្តឆ្លងផុតការត្រួតពិនិត្យគុណភាពដោយជោគជ័យ វានៅតែមានសុវត្ថិភាព និងគុណភាពល្អក្នុងការប្រើប្រាស់។

សូមអរគុណចំពោះអ្វីគ្រប់យ៉ាងដែលអ្នកធ្វើ ដើម្បីរក្សាសហគមន៍របស់យើងឱ្យមានសុវត្ថិភាព និងសុខភាពល្អ!

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

DOH 421-037 February 2023 Khmer